EIE-06-256 REEPRO

# ការជំរុញប្រសិទ្ធភាពប្រើប្រាស់ថាមពលថ្មី នៅប្រទេសកំពុងអភិវឌ្ឍន៍

## វិភាគសមត្ថភាពនៃការសិក្សា-ហិរញ្ញវត្ថុ និង សេដ្ឋកិច្ច

## ក្នុងប្រទេសកម្ពុជា

រៀបរៀងដោយៈ

លោក ជៅ គឹមហេង

លោក សំ ផល្លា

លោក ថាច ជីតារ៉ូ

**អង្គការកែឆ្នៃសំរាម និងការសិក្សានៅកម្ពុជា**

**កក្កដា ២០០៧**

The REEPRO project receives funding from the European Commission within the COOPENER Programme.
The contents of this document are the sole responsibility of the authors and can under no circumstances be regarded as reflection of the position of the Europe Union.

# មាតិកា

1 សេចក្តីផ្តើម ... 1

1.1 ពតិមានទូទៅ ... 1

1.2 សេដ្ឋកិច្ច ... 2

1.3 ការអប់រ ... 3

1.3.1 កម្មវិធីកំណែទម្រង់និងការពង្រីកប្រព័ន្ធអប់រំ ... 3

1.3.2 សាលាបឋមសិក្សា ... 4

1.3.3 អនុវិទ្យាល័យ ... 6

1.3.4 វិទ្យាល័យ ... 8

1.3.5 កំរិតសិក្សាថ្នាក់ឧត្តម ... 8

2 ព្រំដែននៃការវាយតំលៃលើសមត្ថភាពការអប់រំ ... 10

3 ការជ្រើសរើសក្រុមគោលដៅ ... 10

4 នីតិវិធីនៃបញ្ជីសំណួរ ... 11

5 លទ្ធផល ... 11

5.1 ទិន្នន័យទូទៅ ... 11

5.2 ជំនាញ និងកំរិតនៃការសិក្សា ... 14

5.3 កំរិតនៃចំណេះដឹង បទពិសោធន៍ និងសមត្ថភាពផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រង ... 16

5.3.1 គម្រោងថវិកា ការតាមដាន និងការគណនានៃឱកាសថ្លៃដើម: ... 16

5.3.2 ការចុះបញ្ជីក្រុមហ៊ុន ... 17

5.3.3 បច្ចេកទេសហិរញ្ញវត្ថុ ... 19

5.3.3 ការគ្រប់គ្រងក្រុមហ៊ុន ... 20

6 សេចក្តីសន្និដ្ឋានរួម .....21

7 សេចក្តីបន្ថែម.....22

7.1 សេចក្តីបន្ថែម 1: Questionnaire .....22

7.2 សេចក្តីបន្ថែម 2: Excel files with the single results without graphs.....30

8 ឯកសារយោង .....31

# បញ្ជីរូបភាព

រូបភាពទី ១: កម្ពុជា [www.wikipedia.org] .......... 1

រូបភាពទី ២: ចំនួននៃការចុះឈ្មោះចូលរៀនរបស់សាលាបឋមសិក្សា [www.moeys.gov.kh] .......... 5

រូបភាពទី ៣: ចំនួននៃការចុឈ្មោះចូលរៀនរបស់សាលាអនុវិទ្យាល័យ [www.moeys.gov.kh] .......... 7

រូបភាពទី ៤: ចំនួននៃការចុះឈ្មោះចូលរៀនសំរាប់សាលាមធ្យមសិក្សាជាន់ខ្ពស់ .......... 8

រូបភាពទី ៥: សិស្សក្នុងស្ថាប័នរដ្ឋថ្នាក់ឧត្តមសិក្សា .......... 9

រូបភាពទី ៦: ចំនួនសិស្សរៀនក្នុងស្ថាប័នឯកជនថ្នាក់ឧត្តមសិក្សា .......... 9

រូបភាពទី ៧: សម្ភាសន៍បុគ្គលិកពីមុខរបរបច្ចុប្បន .......... 13

រូបភាពទី ៨: ជំនាញសំខាន់នៃការងារ .......... 13

រូបភាពទី ៩: ជំនាញនៃការសិក្សា (វិជ្ជាជីវៈ និងមហាវិទ្យាល័យ) .......... 15

រូបភាពទី ១០: អ្នកចូលរួមវគ្គបណ្តុះបណ្តាល .......... 15

រូបភាពទី ១១: បទពិសោធន៍ក្នុងការចុះបញ្ជីក្រុមហ៊ុន .......... 18

រូបភាពទី ១២: កំរិតយល់ដឹងនៃការងារហិរញ្ញវត្ថុ .......... 19

រូបភាពទី ១៣: ទំហំនៃការគ្រប់គ្រងគម្រោងដែលធ្លាប់មាន .......... 20

# បញ្ជីតារាង

តារាង ១: ពតិមានទូទៅលើអ្នកត្រូវបានសម្ភាសន៏ ....................12

តារាង ២: បទពិសោធន៏ការងារ ....................12

តារាង ៣: កំរិតនៃការសិក្សា ....................14

តារាង ៤: បទពិសោធន៏ និងចំណេះដឹងក្នុងគម្រោងថវិកា និងការតាមដាន និងការគណនានៃឱកាសថ្លៃដើម...16

តារាង ៥: បទពិសោធន៏ និងចំណេះដឹងក្នុងការចុះបញ្ជីក្រុមហ៊ុន....................17

តារាង ៦: ការងារហិរញ្ញវត្ថុ ....................19

តារាង ៧: ការគ្រប់គ្រងក្រុមហ៊ុន ....................20

# បញ្ជីពាក្យគ្រាត់

| | |
|---|---|
| COMPED | អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា |
| ESP | គំរោងយុទ្ធសាស្ត្រការសិក្សា |
| IRRI | ស្ថាប័នស្រាវជ្រាវស្រូវអន្តរជាតិ |
| MoEYS | ក្រសួងអប់រំយុវជន និងកីឡា |
| NAR | អត្រាគ្រប់អាយុចូលរៀន |
| NER | អត្រាអ្នកចុះឈ្មោះចូលរៀន |
| SME | សហគ្រាសទំហំតូច និងមធ្យម |

# 1 សេចក្តីផ្តើម

## 1.1 ពត៌មានទូទៅ

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយដែលស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍ ហើយមានប្រជាពលរដ្ឋជាង ១៥ លាន នាក់ ដែលមានភ្នំពេញជារាជធានី ។ [www.wikipedia.org]

ប្រទេសកម្ពុជាមានព្រំប្រទល់ជាប់ប្រទេសថៃនៅទិសខាងលិច និងទិសខាងជើងឈាងខាងលិច (ទិសនិរតី), ជាប់ប្រទេសឡាវនៅទិសខាងជើងឈាងខាងកើត (ទិសអាគ្នេយ៍), ជាប់ប្រទេសវៀតណាមនៅទិសខាងកើត និងទិសខាងត្បូងឈាងខាងកើត (ទិសឥសាន្ត) ។ នៅទិសខាងត្បូងនៃប្រទេសកម្ពុជាជាប់ជាមួយឈូងសមុទ្រថៃ ។ ភូមិសាស្ត្រនៃប្រទេសកម្ពុជា គឺគ្របដណ្តប់ដោយទន្លេមេគង្គ (ទន្លេធំ) និងទន្លេសាប (បឹងទឹកស្អាត) ដែលជាប្រភពត្រីដ៏សំខាន់ ។ តំបន់ទំនាបនៃប្រទេសកម្ពុជាសម្បូរណ៏ដោយដីមានជីជាតិ មានន័យថា តំបន់ជាច្រើននៅក្នុងប្រទេស ឋិតនៅក្រោមកំរិតកំពស់នៃទឹកសមុទ្រ ដូច្នេះហើយបានជាបឹងទន្លេសាបមានចលនាទឹកហូរត្រឡប់ទៅមកនៅរដូវវស្សាដែលនាំទឹកពីទន្លេមេគង្គទៅកាន់បឹងទន្លេសាប ព្រមទាំងតំបន់ទំនាបនៅពទ្ធ័ជុំវិញ ។

ឧស្សាហកម្មដ៏សំខាន់នៃប្រទេសកម្ពុជាគឺ រោងចក្រកាត់ដេរ និងតំបន់ទេសចរណ៏ ។ ក្នុងឆ្នាំ ២០០៦ មានភ្ញៀវបរទេសប្រមាណជា ១,៧ លាននាក់ តាមការកត់ត្រា ។ ក្នុងឆ្នាំ ២០០៥, ប្រេង និងហ្គាសធម្មជាតិ ដែលត្រូវបានរកឃើញនៅក្នុងដែនទឹកប្រទេសកម្ពុជា ។ ហើយទន្ទឹមនឹងនេះផងដែរក្រុមហ៊ុនពាណិជ្ជកម្ម ក៏ចាប់ផ្តើមដំណើរការដកប្រេងក្នុងឆ្នាំ ២០០៩ ឬនៅដើមឆ្នាំ ២០១០ ។ ចំណូលពីប្រេងអាចក្លាយជាប្រភពនៃផលប៉ះពាល់ដល់សេដ្ឋកិច្ចប្រទេសកម្ពុជានៅថ្ងៃអនាគត ។ [www.wikipedia.org]




**រូបភាពទី ១: កម្ពុជា[www.wikipedia.org]**

## 1.2 សេដ្ឋកិច្ច

ថ្វីបើនៅក្នុងដំណើរការពេលថ្មីៗ សេដ្ឋកិច្ចប្រទេសកម្ពុជាបន្តទទួលរងនូវការធ្លាក់ចុះពីផលប៉ះពាល់នៃសង្គ្រាមស៊ីវិលជាច្រើនទសវត្សរ៍ ការបែកបាក់ផ្ទៃក្នុង និងអំពើពុករលួយដោយឥតឈប់ឈរ ។ ចំណូលជាតិមានការកើនឡើងឆាប់រហ័ស ប៉ុន្តែនូវមានលក្ខណៈទាបនៅឡើយបើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតនៅក្នុងតំបន់ ។ គ្រួសារភាគច្រើននៅតាមជនបទ ពឹងផ្អែកលើដំណាំកសិកម្ម និងវិស័យកសិកម្ម។ ស្រូវ, ត្រី, ព្រៃឈើ, សំលៀកបំពាក់ និងកៅស៊ូ គឺជាការនាំចេញចំបងរបស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក, សិង្ហបូរី, ជប៉ុន, ថៃ, ចិន, ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ដែលជាដៃគូនាំចេញយ៉ាងសំខាន់ ។

សង្គ្រាម និងរបបលទ្ធិផ្តាច់ការ នៅក្នុងទសវត្សរ៍ ១៩៧០ បានបង្កើតការអត់ឃ្លាននៅប្រទេសកម្ពុជា ។ ផ្តល់ភាពអស់សង្ឃឹមដល់គ្រួសារអ្នកស្រែចំការដែលធ្វើអោយខូចខាតអស់នូវពូជស្រូវសំណាប និងគ្រាប់ពូជជាច្រើនប្រភេទផ្សេងៗគ្នានោះ បានក្លាយជាការពិបាកក្នុងការស្វែងរក។ នៅក្នុងទសវត្សរ៍ ១៩៨០ វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) បានរៀបចំបង្ហាញឡើងវិញនូវប្រភេទស្រូវផ្សេងៗគ្នាជាច្រើនជាង ៧៥០ ប្រភេទ ទៅប្រទេសកម្ពុជា ដែលបានមកពីកន្លែងផ្ទុកសំណាបស្រូវនៃប្រទេសហ្វីលីពីន។ គ្រាប់ពូជស្រូវទាំងនេះត្រូវបានប្រមែប្រមូលនៅក្នុងទសវត្សរ៍ ១៩៦០ ។ នៅក្នុងឆ្នាំ ១៩៨៧ រដ្ឋាភិបាលប្រទេសអូស្ត្រាលីបានផ្តល់ជំនួយដល់ IRRI ដើម្បីជួយប្រទេសកម្ពុជាធ្វើអោយប្រសើរឡើងនូវផលិតផលស្រូវ។ នៅឆ្នាំ ២០០០ ប្រទេសកម្ពុជា មានស្រូវល្មមគ្រប់គ្រាន់សំរាប់ខ្លួនម្តងទៀត ។

តាមប្រវត្តិសេដ្ឋកិច្ចប្រទេសកម្ពុជាមានល្បឿនយឺតខ្លាំងនៅក្នុងឆ្នាំ ១៩៩៧-១៩៩៨ ដោយសារតែវិបត្តិនៃសេដ្ឋកិច្ចក្នុងតំបន់, អំពើហិង្សាផ្នែកស៊ីវិល និងវិវាទនយោបាយ ។ អ្នកវិនិយោគបរទេស និងវិស័យទេសចរណ៍ត្រូវធ្លាក់ចុះយ៉ាងខ្លាំង។ ចាប់តាំងពីពេលនោះមកការកើនឡើងនៃសេដ្ឋកិច្ចស្ថិតនៅនឹង ។ នៅក្នុងឆ្នាំ ១៩៩៩ ឆ្នាំទី១នៃសន្តិភាពពេញលេញដំបូងក្នុងរយៈពេល ៣០ ឆ្នាំ, ការបោះជំហ៊ានទៅមុខត្រូវធ្វើទៅលើការកែទម្រង់សេដ្ឋកិច្ច និងដែល មានកំណើនតាមការសន្និដ្ឋានចំនួន ៥%។ ថ្វីបើភាពអណ្តែតការកើនឡើង GDP ពី ៥% ក្នុងឆ្នាំ ២០០០, ៦.៣% ក្នុងឆ្នាំ ២០០១, និង ៥.២% ក្នុងឆ្នាំ ២០០២។ វិស័យទេសចរណ៍គឺជាឧស្សាហកម្មរបស់ប្រទេសកម្ពុជា ដែល កើនឡើងយ៉ាងលឿន, ជាមួយនឹងកាកើនឡើងដល់ទៅ ២១៩ ០០០ នៅឆ្នាំ ១៩៩៧ ទៅ ១០៥៥ ០០០ នៅក្នុងឆ្នាំ ២០០៤។ ក្នុងកំឡុងឆ្នាំ ២០០៣ និង ២០០៤ អត្រានៃការកើនឡើងនៅនឹងត្រឹម ៥%។ ទន្ទឹមពេលមាន អតិផរណា ១.៧% ក្នុងឆ្នាំ ២០០៤ និងនាំចេញបាន ១.៦ កោដិដុល្លាសហរដ្ឋអាមេរិក ។ តាមដែលលិទ្ធផលឆ្នាំ ២០០៥, GDP ចំណូលរបស់ជាតិក្នុងផ្នែក PPP គឺ ២២០០ ដុល្លាសហរដ្ឋអាមេរិក ដែលមានកំរិតថ្នាក់ ១៧៨ (ចេញ ២៣៣) ប្រទេស។

ប្រជាពលរដ្ឋជាញឹកញាប់ជួបប្រទះបញ្ហាខ្វះខាតក្នុងការសិក្សា និងជំនាញផលិត ជាពិសេសអ្នកក្រីក្រដែលប្រកបរបរនៅតំបន់ជនបទ។ អាចបណ្តាលមកពីស្ថានភាពការខ្វះខាតនៃមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ។ ភាពភ័យខ្លាចនៃអស្ថិរភាពនយោបាយកើតឡើងសារជាថ្មី និងការពុករលួយនៅក្នុងជួរដ្ឋាភិបាល ដែលធ្វើអោយអ្នកវិនិយោគបរទេសបាក់ទឹកចិត្ត និងធ្វើអោយមានការពន្យាពេលជំនួយឧបត្ថម្ភមកពីក្រៅប្រទេស ទោះបីជាមានការជំនួយពីអ្នកផ្តល់ជំនួយ មកពីដៃគូទ្វេភាគី និងជំនួយពហុភាគីក៏ដោយ ។ អ្នកផ្តល់ជំនួយសន្យាផ្តល់ទឹកប្រាក់ចំនួន ៥០៤ លាន ដុល្លាសហរដ្ឋអាមេរិក ទៅអោយប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៤ ទន្ទឹមពេលធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ប្រាក់កម្ចីដាច់ដោយឡែក ៨៥០លាន ដុល្លាសហរដ្ឋអាមេរិក ក្នុងការអោយខ្ចី និងជំនួយផ្នែកបច្ចេកទេស ។

ឧស្សាហកម្មទេសចរណ៍ គឺជាប្រភពដ៏សំខាន់ទី២ផងដែរនៃចំណូលជាតិដ៏ច្បាស់លាស់របស់ប្រទេសកម្ពុជា បន្ទាប់ពីឧស្សាហកម្មវាយនភ័ណ្ឌ។ ៥០% នៃអ្នកទេសចរណ៍ដែលបានមកដល់ប្រទេសកម្ពុជា គឺទៅទស្សនាប្រាសាទអង្គរវត្ត និងនៅសេសសល់ទៅភ្នំពេញ។ អ្នកទេសចរណ៍ផ្សេងទៀត បានទៅរួមទាំងក្រុងព្រះសីហនុដែលមានឆ្នេរខ្សាច់ដ៏ស្រស់ស្អាត និងតំបន់ដែលនៅជាប់ជុំវិញកំពត គឺភ្នំបូកគោ។
[www.wikipedia.org].

## 1.3 ការអប់រំ

ការរីកចំរើនផ្នែកវិស័យអប់រំបែបទំនើបនៅមានភាពយឺតយ៉ាវខ្លាំងនៅប្រទេសកម្ពុជា។
អ្នកគ្រប់គ្រងសម័យអាណានិគមបារាំង មិនបានយកចិត្តទុកដាក់ផ្តល់ចំណេះដឹងដល់ខ្មែរឡើយ ។ មិនយូរប៉ុន្មានក្រោយមក ទស្សវត្សទី ១៩៣០ មានវិទ្យាល័យទីមួយត្រូវបានបើក។ យ៉ាងណាមិញ បន្ទាប់ពីបានទទួលឯករាជ្យពីបារាំង រដ្ឋាភិបាលនៃសម្តេច នរោត្តម សីហនុ បានធ្វើការបង្កើនលើវិស័យការអប់រំនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និង ១៩៦០ ។ សាលាបឋម សិក្សា និងមធ្យមសិក្សា បានពង្រីកទៅតាមផ្នែកផ្សេងៗនៃប្រទេស ដែលជាគ្រឹះស្ថានអប់រំជាន់ខ្ពស់ដូចជា គ្រឹះស្ថានវិជ្ជាជីវៈ មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន និងមហាវិទ្យាល័យជាច្រើនបានត្រូវបង្កើត ។ ក្នុងដំណើរការប៉ុន្មានទសវត្សរ៍នេះ ត្រូវបានរាំងស្ទះដោយសារសង្គ្រាមស៊ីវិលផ្តួលរំលំសម្តេច សីហនុ នៅក្នុងឆ្នាំ ១៩៧០ ហើយបន្ទាប់មកត្រូវកំទេចដោយសាររបបខ្មែរក្រហម ។

### 1.3.1 កម្មវិធីកំណែទម្រង់ និងការពង្រីកប្រព័ន្ធអប់រំ

ការផ្លាស់ប្តូរគោលនយោបាយ និងសេដ្ឋកិច្ចសង្គម បានធ្វើអោយការកំណែទម្រង់នៃប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាទទួលបានជោគជ័យ។ មុនឆ្នាំ ១៩៧៥ ប្រទេសកម្ពុជាបានរក្សាទុកនូវប្រព័ន្ធមូលដ្ឋានសិក្សាសំខាន់ៗរបស់បារាំងដែលជាតម្រូវការរយៈពេល ១៣ ឆ្នាំ នៃការសិក្សា (៦+៤+២+១) ជាមួយនឹងការប្រឡងសំខាន់ៗចំនួន ៤ ឬ ៥។

បន្ទាប់មកនៅឆ្នាំ ១៩៧៩ ក្រសួងអប់រំបានធ្វើការពិចារណានូវតម្រូវការបន្ទាន់របស់ប្រទេសប្រតិបត្តិប្រព័ន្ធសិក្សាសំរាប់រយៈពេល ១០ ឆ្នាំ (៤+៣+៣) ហើយបន្ទាប់មកក៏មានការពង្រីកប្រព័ន្ធអប់រំដល់ ១១ ឆ្នាំ ចាប់ពីឆ្នាំ ១៩៨៦ ទៅ ១៩៩៦ ។

ក្រសួងនៅតែបន្តការធ្វើអោយប្រសើរឡើងផ្នែកប្រព័ន្ធអប់រំ ។ កម្មវិធីសិក្សាត្រូវបានកែទម្រង់ដោយបានអភិវឌ្ឍសៀវភៅសិក្សាថ្មី និងការផ្តល់ជំនាញបង្រៀនថ្មី ដល់គ្រូបង្រៀនសំរាប់ជាមូលដ្ឋាន ដើម្បីណែនាំនូវប្រព័ន្ធសិក្សាថ្មីមានរយៈពេល ១២ឆ្នាំ (៦+៣+៣) នៅក្នុងឆ្នាំ ១៩៩៦-១៩៩៧ នៃឆ្នាំសិក្សា ។ ប្រព័ន្ធសិក្សាថ្មីបានបង្កើនចំនួនម៉ោងសិក្សាសំរាប់គ្រប់ថ្នាក់បឋមសិក្សាទាំងអស់ ។

នៅក្នុងគម្រោងប្រព័ន្ធសិក្សាថ្មីរយៈពេល ១២ ឆ្នាំនេះ ក្នុងមួយឆ្នាំសិក្សា គឺរៀនរយៈពេល ៣៨ សប្តាហ៍, ជាមួយការរៀន ៥ ថ្ងៃក្នុង ១ សប្តាហ៍, ៦ ពេលក្នុងការរៀនមួយថ្ងៃ និងពេលនៃការសិក្សានិមួយៗមាន ៤៥ នាទី ។ ក្រោមកម្មវិធីការសិក្សាចាស់ ក្នុង ១ឆ្នាំ ការសិក្សាមានត្រឹមតែ ៣២ ទៅ ៣៣ សប្តាហ៍ប៉ុណ្ណោះហើយកូនសិស្សចូលរៀនតែ ៤ ម៉ោង ក្នុងមួយថ្ងៃនៃការសិក្សា។ ក្នុងការពិចារណានូវការខ្វះបន្ទប់រៀន ក្រសួងបានអនុញ្ញាតអោយគ្រូបង្រៀនតែ ៥ ពេល ក្នុងមួយថ្ងៃ និងពេលនិមួយៗបញ្ចប់ត្រឹម ៤០ នាទីប៉ុណ្ណោះ ។

យោងទៅតាមការស្ទាបស្ទង់ធ្វើការសម្រុះសម្រួលរួមគ្នា នៅខែ មិនា ឆ្នាំ១៩៩៩ ដោយនាយកដ្ឋានផែនការរបស់ក្រសួងងប់រំ និងគម្រោងធនាគារពិភពលោក កម្មវិធីសិក្សាថ្មីនេះអាចធ្វើទៅបាន ១១៤០ ពេល នៃការសិក្សាដែល ស្មើនឹង ៨៥៥ ពេល នៃចំនួនម៉ោងបង្រៀន។ ការបង្រៀន និងម៉ោងរៀនត្រូវរៀបចំដោយក្រសួងអប់រំគឺមាន ៩៥០ ពេលនៃម៉ោងសិក្សា ឬ ៦៣៣ នៃម៉ោងគ្រូបង្រៀន ក្នុងការអនុវត្តមានតែ ៨២៥ ពេលនៃម៉ោងសិក្សា នៃ ម៉ោងគ្រូបង្រៀន ៥៣៣ ដែលមាន ។

ជាការពិតចំនួននៃការអនុវត្តការបង្រៀន និងម៉ោងសិក្សា នៅមានកំរិតទាបខ្លាំងជាងអ្វីដែលក្រសួងបានតម្រូវជាចំនួនតួលេខមួយប្រសើរនៃកំរិតបង្រៀនតិចជាង ៥ ពេលនៃចំនួនការសិក្សាក្នុងថ្ងៃ។ ការឈប់សំរាករយៈពេលយូរ នៅតែមានផលប៉ះពាល់ដល់ម៉ោងសិក្សា។ [http://www.moeys.gov.kh].

### 1.3.2 សាលាបឋមសិក្សា

តាមទិន្នន័យស្ថិតិសំរាប់ឆ្នាំ ២០០៤-២០០៥ នៃឆ្នាំសិក្សាបង្ហាញអោយឃើញថា ចំនួនតួលេខសរុបនៃសាលាបឋមសិក្សាមាន ៦១៨០ ដែលមានសិស្សចំនួន ២,៦៨២,១២៩ ។ នេះរាប់បញ្ចូលសិស្សស្រីចំនួន ១,២៦៦,៤២០ គឺស្មើនឹង ៤៧% នៃចំនួនបង្ហាញសរុប ដែលកំរិតនេះការចុះឈ្មោះចូលរៀននៃសិស្សប្រុសនិងសិស្សស្រី មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ចំនួនបុគ្គលិកនៅសាលាបឋមសិក្សាមាន ៦០៨៤១ (២២៩៣៤ ស្រី) នៃបុគ្គលិកគ្រូ

បង្រៀនគឺ ៥០១៤០ (២០៦៧៨ ស្រី ឬ ៤១.២៤%) ក្រសួងអប់រំយុវជន និងកីឡា កំពុងស្វែងរកការវាយតំលៃដើម្បីកំណត់អោយច្បាស់នូវសមមាត្រនៃបុគ្គលិកបង្រៀន និងបុគ្គលិកមិនបានបង្រៀន ។

ការចុះឈ្មោះចូលរៀនបានកើនឡើងពី ២.៤ លាន ក្នុងឆ្នាំ ២០០០-២០០១ ទៅ ២,៧លាន ក្នុងឆ្នាំ ២០០២-២០០៣។ ប៉ុន្តែមានការថយចុះបន្តិចបន្តួច ដោយសារការកើនឡើងនៃប្រជាពលរដ្ឋចុះអន់ថយ ប្រមាណ ៥-៦ឆ្នាំមុននេះ ។

នៅក្នុងឆ្នាំសិក្សា ២០០៤-២០០៥ អត្រាដែលមានសិទ្ធិចុះឈ្មោះសរុប សំរាប់សាលាបឋមសិក្សាគឺ ៨១% ដែលតិចជាងទិសដៅដែលបានកំណត់ទុកជាមុន ៩០% ហើយវិស័យសំខាន់បំផុតដែលធ្វើអោយមានការព្រួយបារម្ភ ពីព្រោះថ្នាក់ទីមួយ មានឥទ្ធិពលដល់កូនសិស្សដែលរៀនថ្នាក់បន្តបន្ទាប់ទៀត។ អត្រាដែលមានសិទ្ធិចុះឈ្មោះសរុបសំរាប់សិស្សស្រីគឺ ៧៩% បើប្រៀបធៀបទៅនឹងទិសដៅដែលបានកំណត់ទុកនៃ ៩០%។

អត្រាដែលបានមកពីការចុះឈ្មោះចូលរៀន ៩១.៩% នៅឆ្នាំ ២០០៤-២០០៥ ជិតដល់ ៩២%, ហើយសំរាប់ក្មេងស្រីមាន ៩០.៧% បើប្រៀបធៀបទិសដៅដែលបានកំណត់ទុកនៃ ៩១%។ ទិសដៅដែលបានកំណត់ទុកនៃការចុះឈ្មោះចូលរៀនសំរាប់ថ្នាក់បឋមនៅក្នុងឆ្នាំសិក្សា ២០០៤-២០០៥ មាន ៩៥% (ទីក្រុង,) ៩២% (ជនបទ) និង ៧៦% (តំបន់ដាច់ស្រយាល)។ តាមក្រាហ្វិក (រូបភាពទី ២) ខាងក្រោមបានបង្ហាញថាការបង្រៀនសំរាប់បឋមសិក្សានៅជនបទ និងតំបន់ដាច់ស្រយាលហួសពីទិសដៅដែលបានកំណត់ប៉ុន្តែវាទាបជាងគ្រោងការកំណត់សំរាប់តំបន់ទីក្រុង។ ការប្រៀបធៀបឆ្នាំសិក្សា ២០០០-២០០១ នឹងឆ្នាំសិក្សា ២០០៤-២០០៥ អត្រាដែលបានមកពីការចុះឈ្មោះចូលរៀនបានឡើងដល់ទៅជាង ២០% នៅតំបន់ដាច់ស្រយាលនិង ៨% នៅតំបន់ជនបទ ទន្ទឹម និងការកើនឡើងនៅតំបន់ ទីក្រុង ផងដែរកំឡុង ពេលដូចគ្នាបានប្រហែលជា ៥%។




**រូបភាពទី ២: ចំនួននៃការចុះឈ្មោះចូលរៀនរបស់សាលាបឋមសិក្សា [www.moeys.gov.kh]**

### 1.3.3 អនុវិទ្យាល័យ

តាមគោលនយោបាយស្រដៀងគ្នានេះដែរ និងយុទ្ធសាស្ត្រនៅក្នុងបឋមសិក្សានោះ បានត្រូវកើនឡើង ៩២ សាលារៀន នៅក្នុងឆ្នាំ២០០៤-២០០៥ មានសិស្សចំនួន ៩៧៨ មានកំរិតសិក្សាត្រឹមអនុវិទ្យាល័យ។ ចំនួនសរុបនៃសិស្សដែលចុះឈ្មោះចូលរៀនបាន ៥២៨,៩៤០ រាប់បញ្ចូលទាំងសិស្សស្រីចំនួន ២៣០,០៤៨ ផងដែរ ។

អត្រាចុះឈ្មោះចូលរៀនត្រូវបានធ្វើទៅតាមគំរោងយុទ្ធសាស្ត្រការសិក្សាក្នុងឆ្នាំ ២០០៤-២០០៨ សំរាប់ឆ្នាំសិក្សា ២០០៤-២០០៥ បាន ៥០% សំរាប់តំបន់ទីក្រុង (៤៩% សិស្សស្រី), ៣៥% សំរាប់តំបន់ជនបទ (៣៥% សិស្សស្រី) និង ១៥% សំរាប់តំបន់ដាច់ស្រយាល (១៥% សិស្សស្រី)។ តាមលទ្ធផលនេះបង្ហាញថា មិនបានដល់គោលដៅតាមផែនការកំណត់។

មានការកើនឡើងយ៉ាងខ្លាំងនៃចំនួនសិស្សផ្នែកអនុវិទ្យាល័យ ដោយការចុះឈ្មោះចូលរៀនកើនពី ២៣៣,២៧៨ នៅឆ្នាំ ១៩៩៩-២០០០ ដល់ទៅ ៥២៨,៩៤០ នៅឆ្នាំ ២០០៤-២០០៥ គឺកើនបន្ថែម ១២៦% លើសពីពេលមុន។ ទាំងនេះនាំអោយមានការកើនឡើងអត្រាចុះឈ្មោះចូលរៀន ២៦.១០% (ស្រី ៩.៣០%) ដែលមានកំរិតខ្ពស់ជាងឆ្នាំ ២០០៣-២០០៤ ប៉ុន្តែទាបជាងតាមគោលដៅកំណត់ ៤០%។

ថ្វីបើនៅក្នុងពេលថ្មីៗនេះ មធ្យោបាយដែលសាលាបានពង្រីកសំរាប់ថ្នាក់ទី ៧-៩ គឺវាមិនទាន់គ្រប់គ្រាន់ទៅនឹងតំរូវការនៃការឆ្លើយតបនៅឡើយទេ ។ មានតែ ៧៤៩ ឃុំ មានសាលាអនុវិទ្យាល័យសរុបចំនួន ១,៦២១។ នៅតំបន់ដាច់ស្រយាល អត្រាដែលបានមកពីការចុះឈ្មោះមានត្រឹមតែ ៣.៩%, ឧទាហរណ៍ ជាង ៩៥% នៃក្មេងអាយុ ១២-១៤ឆ្នាំ មិនបានទៅចុះឈ្មោះចូលរៀននៅបណ្តាលសាលាអនុវិទ្យាល័យ ដោយសារកង្វះខាតសាលាវិទ្យាល័យនៅក្នុងតំបន់នោះ។ ការសិក្សានៅក្នុងកំរិតអនុវិទ្យាល័យមានលក្ខណៈគ្រប់គ្រាន់ទោះជាមានគ្រូជំនាញតិចនៅតាមសាលាមួយចំនួននៅតំបន់មិនដែលមានផលវិបាកក៏ដោយ។

សាលាភាគច្រើនគ្រប់គ្រងបុគ្គលិក មានប្រសិទ្ធភាពដោយសារមានការចូលរួមពីសហគមន៏។ ទោះជាយ៉ាងណាក៏ដោយ ២០% នៃសាលាទើបបង្កើតថ្មី នៅតែមានបញ្ហាលើការខ្វះខាតបទពិសោធន៏ ដែលមិនមានការបណ្តុះបណ្តាលគ្រប់គ្រាន់នៅតាមសាលាបង្គោល។ សិស្សច្រើនសង្កត់ធ្ងន់ទៅលើវិធីសាស្ត្រដែលមិនមែនជាលក្ខណៈល្អសំរាប់ការអនុវត្តន៏នៅក្នុងសាលាដោយសារចំនួនថ្នាក់រៀនច្រើន មានសៀវភៅរៀនតិច ប្រដាប់ប្រដារៀនសូត្រ និង បណ្ណាល័យ។ ការកើនឡើងនូវបរិមាណសិស្សដោយសារការធ្លាក់ចុះនូវគុណភាពនៃការសិក្សាអនុវិទ្យាល័យ និង តុល្យភាពរវាងចំនួនបរិមាណ និងគុណភាព។ នៅឆ្នាំសិក្សា ២០០៤-២០០៥ ស្ថិតិបានបង្ហាញថា ៨៧១ នៃ ១៦២១ ឃុំ មិនមានសាលាអនុវិទ្យាល័យ។




រូបភាពទី ៣:    ចំនួននៃការចុះឈ្មោះចូលរៀនរបស់សាលាអនុវិទ្យាល័យ [www.moeys.gov.kh]

### 1.3.4 វិទ្យាល័យ

២៣២ វិទ្យាល័យមាននៅក្នុងឆ្នាំ ២០០៤-២០០៥ បើប្រៀបធៀបទៅ ២១២ ក្នុងឆ្នាំ ២០០៣-២០០៤។ ចំនួនតួលេខសរុបនៃសិស្សទាំងអស់គឺ ១៧៧,១២៩ ដោយរួមទាំង ៦៦,៣២៤ ស្រី។

អត្រាចុះឈ្មោះចូលរៀនគឺ ៩.៣% (៧.៩%ស្រី) ដែលមានលក្ខណៈខ្ពស់ជាងការសិក្សាឆ្នាំមុន និងតិចជាងគោលដៅបានកំនត់ ១៥% (១៤% ស្រី)។ ការចុះឈ្មោះបានកើនឡើងតិចតួច បើប្រៀបធៀបទៅនឹង ឆ្នាំ២០០៣-២០០៤។ មូលហេតុដោយសារភាពក្រីក្រ ហើយតំរូវការទីផ្សារពលកម្ម និងមានចំនួនស្រីតិចនៅតាមតំបន់ដាច់ស្រយាល។ ៤៦ ស្រុកមិនមានវិទ្យាល័យនៅក្នុងឆ្នាំ ២០០៤-២០០៥។




**រូបភាពទី ៤: ចំនួននៃការចុះឈ្មោះចូលរៀនសំរាប់សាលាមធ្យមសិក្សាជាន់ខ្ពស់**

### 1.3.5 កំរិតសិក្សាថ្នាក់ឧត្តម

ស្ថាប័នជាន់ខ្ពស់សរុបមាន ៤៤ ក្នុងឆ្នាំ ២០០៤-២០០៥ ហើយ ១៣ ជាស្ថានប័នរដ្ឋ និង ៣១ ជាស្ថាប័នឯកជន។ ទាំងអស់នេះបានបែងចែកលើ ១១ ខេត្ត-ក្រុង និងផ្តល់ឱកាសអោយសិស្សនៅតាមតំបន់ដើម្បីបន្តការសិក្សារបស់ពួកគេក្នុងកំរិតឧត្តម។




រូបភាពទី ៥:    សិស្សក្នុងស្ថាប័នរដ្ឋថ្នាក់ឧត្តមសិក្សា




រូបភាពទី ៦:    ចំនួនសិស្សរៀនក្នុងស្ថាប័នឯកជនថ្នាក់ឧត្តមសិក្សា

រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានអនុវត្តតាមគោលនយោបាយវិស័យឯកជន ដែលមានប្រសិទ្ធភាពជាវិជ្ជមាននៅប្រព័ន្ធឧត្តមសិក្សា។ ប៉ុន្មានឆ្នាំចុងក្រោយស្ថាប័នឯកជនបានកាត់បន្ថយសិស្សដែលរៀននៅថ្នាក់ឧត្តមសិក្សារដ្ឋ។ នៅក្នុង ឆ្នាំ ២០០៤-២០០៥ ចំនួនសរុបនៃសិស្សដែលបង់លុយក្នុងឧត្តមសិក្សាឯកជនមាន ៣៨,៧២២។

ជាមួយគ្នានេះផងដែរ ក្រសួងអប់រំយុវជន និងកីឡា ព្យាយាមសម្របសម្រួលនូវដំណើរការបណ្តុះធនធានទៅក្នុងថ្នាក់ឧត្តមសិក្សា ដើម្បីពង្រីកការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់ថ្ងៃអនាគតនៃប្រទេស។ ក្រសួងអប់រំយុវជន និងកីឡា បានផ្តល់អាហារូបករណ៍ជាច្រើនដើម្បីជ្រើសរើស សិស្សក្រីក្រ សិស្សស្រី សិស្សមកពីតំបន់ដាច់ស្រយាល និងបាន សាងសង់ការស្នាក់នៅផងដែរជាពិសេស សំរាប់សិស្សក្រីក្រ និងសំរាប់សិស្សស្រី។

## 2 ព្រំដែននៃការវាយតំលៃលើសមត្ថភាពការអប់រំ

ការវាយតំលៃនៃការសិក្សាទាក់ទងនឹងចំណេះផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រង បានធ្វើក្នុងក្រុមដែលបានកំណត់ ដូចជាអ្នកបណ្តុះបណ្តាលសហគមន៍ពាក់ព័ន្ធ។ លទ្ធផលនៃការវាយតំលៃនឹងទុកជាពតិមានផ្នែកសេដ្ឋកិច្ច នៃមេរៀនវគ្គបណ្តុះបណ្តាល និងដំណើរការផ្សេងៗទៀតនៅក្នុងគម្រោង ។

## 3 ការជ្រើសរើសក្រុមគោលដៅ

បន្ទាប់ពីធ្វើការពិភាក្សាជាច្រើនដងអំពីក្រុមដែលត្រូវវាយតាមបញ្ជីសំនួរ ការវាយតំលៃសមត្ថភាព ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច COMPED បានសំរេចបង្កើតចំនួន ៧០ច្បាប់ នៃបញ្ជីសំនួរ ដើម្បីសួរដល់សិប្បករ និងសហគ្រាស ។ អ្នកទាំងនេះរស់នៅក្នុងក្រុងភ្នំពេញ និងខេត្តពោធិសាត់។ មុននឹងធ្វើការជ្រើសរើស COMPED បានទៅសាកសួរសិប្បករ និងសហគ្រាសមួយចំនួននៅហាង និងកន្លែងធ្វើការរបស់ពួកគេហើយផ្តល់ពតិមាន ដល់ពួកគាត់អំពីការស្នើសុំ ដើម្បី មានទំនុកចិត្តផ្សេងៗក្នុងការទទួលយកពតិមានជាលទ្ធផលបាន។ ប្រសិនបើពួកគេមានបំណងចូលរួមក្នុងការវាយ តំលៃសមត្ថភាពនៃការសិក្សាទៅក្នុងគម្រោង "ការជំរុញប្រសិទ្ធភាពប្រើប្រាស់នៃថាមពល ប្រើប្រាស់ថ្មីក្នុងប្រទេស កំពុងអភិវឌ្ឍន៍" (REEPRO) ពួកគេបានផ្តល់ពេលវេលាលើបញ្ជីសំណួរ។ យ៉ាងណាមិញ បុគ្គលិករបស់ COMPED នឹងបន្តនូវការពន្យល់ដល់អ្នកដែលមានចំណាប់អារម្មណ៍លើគម្រោងនេះផងដែរ ។ ចុងបញ្ចប់ COMPED បាន សំរេចបញ្ជីសំនួរសំរាប់មនុស្ស ៦០ នាក់ ខុសពីអ្វីដែលយើងបានគិតថានឹងសួរមនុស្ស ៧០ នាក់ ។

# 4 នីតិវិធីនៃបញ្ជីសំណួរ

បញ្ជីសំណួរនៃការវាយតំលៃសមត្ថភាពការការសិក្សា ត្រូវបានទទួលនូវថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០០៧ និងបានបញ្ចប់ការបកប្រែជាភាសាខ្មែរដោយ COMPED នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០០៧ ។ បន្ទាប់ពីនោះ ការស្ទង់មតិបានអនុវត្តដោយបុគ្គលិករបស់ COMPED ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០០៧ ។ COMPED បានស្វែងរកទីតាំងសមស្របជាច្រើនសំរាប់ធ្វើការសម្ភាសន៏ ជាចុងក្រោយគោលដៅ ៣ ត្រូវបានធ្វើការជ្រើសរើសគឺៈ យានដ្ឋានជួសជុលរថយន្តមានទីតាំងស្ថិតនៅផ្សារដេប៉ូ, ហាងលក់តុ ទូ នៅសង្កាត់បឹងត្របែក និងសិប្បកម្មដែកនៅព្រែកលៀប ដែលទាំងអស់នេះស្ថិតនៅក្នុងក្រុងភ្នំពេញ។ យើងបានទៅរកអ្នកសម្ភាសន៏ដល់ទីកន្លែងរបស់ពួកគាត់ និងសុំពួកគាត់ដើម្បីចំណាយពេលបំពេញបញ្ជីសំណួរ។ អ្នកសម្ភាសន៏ទាំងអស់បានទទួលនូវការពន្យល់សង្ខេបអំពីបញ្ជីសំនួរ អ្នកដែលត្រូវបានសួរមួយចំនួនមិនមានការចាប់អារម្មណ៏លើការស្ទាបស្ទង់ឡើយ ដោយសារជាប់រវល់ និងគិតថា COMPED ធ្វើការស្រាវជ្រាវពិពតិមានមិនប្រក្រតីរបស់ពួកគាត់។ ភាគច្រើននៃអ្នកសម្ភាសន៏មានអារម្មណ៏រីករាយក្នុងការចូលរួមស្ទង់មតិ និងបានសួរមកវិញថា តើពួកគេអាចប្រើថាមពលថ្មីយ៉ាងដូចម៉េច? ហើយនៅពេលណា? ភាគច្រើននៃពួកគាត់មានចំណាប់អារម្មណ៏ ទៅលើការដាក់បន្ទះពន្លឺ ព្រះអាទិត្យ។ ចុងបញ្ចប់ ២០នាក់ ត្រូវបានធ្វើការសម្ភាសន៏នៅភ្នំពេញ និង៤០នាក់ទៀត នៅខេត្តពោធិសាត់ ពីព្រោះកន្លែងនោះ មានសិប្បករច្រើន ឧទាហរណ៏ដូចជា ជាងចំលាក់, អ្នកធ្វើថ្មកែវ, អ្នកលក់ទឹកកក, អ្នកលក់ឈើ និងអ្នកចែកចាយ អគ្គិសនី ។

# 5 លទ្ធផល

ទោះជាយ៉ាងណាក៏ដោយបញ្ជីសំនួរត្រូវបានបំពេញចប់សព្វគ្រប់ ហើយបុគ្គលិក COMPED បានទទួលលទ្ធផលជាវិជ្ជមានពីការពិភាក្សា។ ភាគច្រើននៃអ្នកសម្ភាសន៏មានចំណាប់អារម្មណ៏ទៅនឹងប្រភពថាមពលថ្មីនេះ។ បន្ទះពន្លឺព្រះអាទិត្យ គឺជាចំណាប់អារម្មណ៏សំខាន់សំរាប់ប្រជាជនកម្ពុជា ។ ម្យ៉ាងទៀតគំរោង REEPRO បានត្រូវទទួលស្គាល់ ជាពិសេសនៅតំបន់ជនបទ។

## 5.1 ទិន្នន័យទូទៅ

<u>ចំនួនអ្នកធ្វើសម្ភាសន៏</u>: ៦០នាក់ បានត្រូវធ្វើការសម្ភាសន៏, ២៤ នាក់ (៤០%) ជាស្ត្រី និង ៣៦ នាក់ ជាបុរស (៦០%)។ ១៧ នាក់ (២៨.៣៣%) នៃអ្នកត្រូវបានសម្ភាសន៏ មានអាយុចាប់ពី ៤០ ទៅ ៥០ ឆ្នាំ ជាបុរស និង ៥នាក់ (៨.៣៣%) ជាស្ត្រី , ៧ នាក់ (១១.៦៦%) នៃអ្នកត្រូវបានសម្ភាសន៏មានអាយុចាប់ពី ២១ ទៅ ២៩ ឆ្នាំ ជាបុរស និង ១៣ នាក់ (២១.៦៦%) ជាស្ត្រី។ អាយុពី ៣០ ទៅ ៤០ឆ្នាំ មាន ១២ នាក់ (២០%) ជាបុរស និង

៦នាក់ (១០%) ជាស្ត្រី ។ ជាមធ្យមគឺ អាយុ ៣៧ ឆ្នាំ ទន្ទឹមនិងមនុស្សក្មេងជាងគេ និងមនុស្សចាស់ជាងគេ នៃអ្នកត្រូវបានសម្ភាសន៍មានអាយុ ២៤ ឆ្នាំ និង ៤៨ឆ្នាំ។

**តារាង ១:     ពតិមានទូទៅលើអ្នកត្រូវបានសម្ភាសន៍**

| | តួលេខ | ភាគរយ |
|---|---|---|
| **ភេទ** | | |
| ប្រុស | ៣៦ | ៦០% |
| ស្រី | ២៤ | ៤០% |
| **អាយុ** | | |
| អាយុក្រោម ៤០ ឆ្នាំ | ៤២ | ៥៥% |
| ចាប់ពី ៤០-៥០ ឆ្នាំ | ១៨ | ៣៤% |
| អាយុលើ ៥០ ឆ្នាំ | 0 | 0% |
| មនុស្សក្មេង | ២៤ ឆ្នាំ | |
| មនុស្សចាស់ | ៤៨ ឆ្នាំ | |
| អាយុមធ្យម | ៣៧ ឆ្នាំ | |

**តារាង ២:     បទពិសោធន៍ការងារ**

| **បទពិសោធន៍ការងារក្នុងមុខងារបច្ចុប្បន្ន** | | |
|---|---|---|
| អប្បរមា | ២ ឆ្នាំ | ៣ (៥%) |
| អតិបរមា | ២៥ ឆ្នាំ | ១ (១.៦៦%) |
| មធ្យមភាគ | ៩ ឆ្នាំ | |
| ក្រោម ១០ ឆ្នាំ | ៣១ | ៥១.៦៦% |
| ១០-២០ ឆ្នាំ | ២៧ | ៤៦.៦៦% |
| លើ ២០ ឆ្នាំ | ២ | ៣.៣៣% |
| បទពិសោធន៍ការងារពីមុន | ១០ | |

<u>មុខរបរ</u>: ដូចបានរៀបរាប់ខាងលើមាន សហគ្រាស និងសិប្បកម្ម នៅក្រុងភ្នំពេញ និងខេត្តពោធិសាត់ ស្ទើរតែពាក់កណ្តាលនៃអ្នកត្រូវបានសម្ភាសន៍ គឺជាជាងចំលាក់មាន ២៤ នាក់ (៤០%) ជាងកំបោរថ្មកែវ ១៧ នាក់

(២៨.៣៣%) ។ ម្ចាស់យានដ្ឋានជួសជុលរថយន្ត ៥ នាក់ (៨.៣៣%) និងម្ចាស់សិប្បកម្មដែក ៤ នាក់ (៦.៦៦%) និងអ្នកលក់ឈើ អ្នកលក់ទឹកកក និងអ្នកលក់គ្រឿងតុទូ គឺដូចគ្នា ៣ នាក់ (៥%) រីឯអ្នកចែក-ចាយភ្លើងអគ្គិសនី មានតិចបំផុត គឺ ១នាក់ (១.៦៦%) ។




**រូបភាពទី ៧: សម្ភាសន៍បុគ្គលិកពីមុខរបរបច្ចុប្បន្ន**

<u>បទពិសោធន៍ការងារ:</u> ១ នាក់ ក្នុងចំណោមអ្នកត្រូវបានសម្ភាសន៍ ៦0នាក់ មានបទពិសោធន៍រយៈពេលយូរជាងគេ ដល់ទៅ ២៥ ឆ្នាំ ស្មើនឹង (១.៦៦%) ដែលភាគច្រើននៃអ្នកត្រូវបានសម្ភាសន៍ (៣១ នាក់ ស្មើនឹង ៥១.៦៦%) មានបទពិសោធន៍ក្រោម ១០ឆ្នាំ និង ២៧ នាក់ (៤៦.៦៦%) មានបទពិសោធន៍ចន្លោះ ១០-២០ ឆ្នាំ ។




**រូបភាពទី ៨: ជំនាញសំខាន់នៃការងារ**

## 5.2 ជំនាញ និងកំរិតនៃការសិក្សា

កំរិតនៃការសិក្សា: ភាគច្រើននៃអ្នកត្រូវបានសម្ភាសន៍បានបញ្ចប់ថ្នាក់អនុវិទ្យាល័យមាន ២៥ នាក់ (៤១.៦៦%), ថ្នាក់វិទ្យាល័យមាន ១៨ នាក់ (៣០%) និង ថ្នាក់បឋមមាន ១៤នាក់ (២៣.៣៣%) ។ ២នាក់ (៣.៣៣%) ទទួលបានសញ្ញាបត្របរិញ្ញា និង ១ នាក់ បានបញ្ចប់ថ្នាក់អនុបណ្ឌិត ។

**តារាង ៣: កំរិតនៃការសិក្សា**

| ជំនាញការសិក្សា | ចំនួន | % | សំគាល់ |
|---|---|---|---|
| វិជ្ជាជីវៈ | 0 | | |
| បឋម | 14 | 23.33% | ជាងចំលាក់, ជាងថ្មកែវ, អ្នកលក់ឈើ, អ្នកលក់ទឹកកក |
| មធ្យម | 25 | 41.66% | ម្ចាស់យានដ្ឋានជួសជុលរថយន្ត, ជាងចំលាក់, ថ្មកែវ, អ្នកលក់ឈើ, អ្នកលក់ទឹកកក, អ្នកលក់តុទូ |
| វិទ្យាល័យ | 18 | 30% | ម្ចាស់យានដ្ឋានជួសជុលរថយន្ត, ជាងចំលាក់, ថ្មកែវ, អ្នកលក់ឈើ, អ្នកលក់តុទូ និងអ្នកចែកចាយអគ្គិសនី, សិប្បកម្មដែក |
| មហាវិទ្យាល័យ | | | |
| បរិញ្ញាបត្រ | 2 | 3.33% | ម្ចាស់យានដ្ឋានជួសជុលរថយន្ត, សិប្បកម្មដែក |
| អនុបណ្ឌិត | 1 | 1.66% | សិប្បកម្មដែក |
| បណ្ឌិត | 0 | | |

**ជំនាញនៃការសិក្សា :** ជំនាញនៃវិជ្ជាជីវៈ និងការសិក្សានៅមហាវិទ្យាល័យ នៃអ្នកដែលត្រូវបានធ្វើសម្ភាសន៍គឺបង្ហាញនៅក្នុងរូបភាពទី ៩ ។ យើងអាចឃើញថា យ៉ាងហោចណាស់ ១៣.៣៣% នៃអ្នកដែលបានធ្វើសម្ភាសន៍មានសាវតាជាគ្រូបង្រៀន, ១៨.៣៣% ទាក់ទងនិងវិទ្យាសាស្ត្រមនុស្ស, ៣៣.៣៣% មានការសិក្សាប្រភេទផ្សេងៗគ្នា ឧទាហរណ៏ដូចជា: ជាងកាត់ដេរ ជាងចំលាក់ ជាងឈើ ។ ៣៥% ទទួលចំណេះដឹងផ្នែកជំនួញ ឬការគ្រប់គ្រង ។




**រូបភាពទី ៩:** **ជំនាញនៃការសិក្សា (វិជ្ជាជីវៈ និងមហាវិទ្យាល័យ)**

រូបភាពទី ១០ បានបង្ហាញអំពីការចូលរួមនៃអ្នកត្រូវបានសម្ភាសន៏ក្នុងវគ្គបណ្តុះបណ្តាលជំនាញ។ ៣០% ឬ១៨ នាក់ ចូលរួមវគ្គបណ្តុះបណ្តាលលើមុខវិជ្ជា គណនេយ្យ គ្រប់គ្រង និង ហិរញ្ញវត្ថុ រយៈពេលពី ១ ទៅ ៣ ខែ។ ១២ នាក់ ឬ ២០% រៀនរយៈពេល ១សប្តាហ៏ ទៅ ១ខែ នៃមុខវិជ្ជា ។ ៣០ នាក់ ឬ ៥០% នៃអ្នកត្រូវបានសម្ភាសន៏មាន ចំណេះ និងការយល់ដឹងអំពីហិរញ្ញវត្ថុតែបន្តិចបន្តួច គណនេយ្យ និងការគ្រប់គ្រង ដោយធ្វើការសិក្សាខ្លួនឯង ការហ្វឹកហ្វឺន និងការពង្រីកចំណេះដឹងអោយល្អ ឬដោយនរណាម្នាក់ជួយបន្ថែម ប៉ុន្តែមិនដែលបានចូលរៀនមុខវិជ្ជា ទាំងនេះទេ ។




**រូបភាពទី ១០:** **អ្នកចូលរួមវគ្គបណ្តុះបណ្តាល**

## 5.3 កំរិតនៃចំណេះដឹង បទពិសោធន៏ និងសមត្ថភាពផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រង

### 5.3.1 គម្រោងថវិកា ការតាមដាន និងការគណនានៃឱកាសថ្លៃដើម:

លទ្ធផលនៃការស្ទង់មតិបានបង្ហាញអោយឃើញថា អ្នកសម្ភាសន៏ទាំងអស់មានចំណេះដឹងផ្នែកគណនេយ្យ ការគ្រប់គ្រង និងហិរញ្ញវត្ថុ។ ថ្វីបើពួកគេដឹងថាមានវគ្គសិក្សាទាំងអស់នេះ និងមានមនុស្សមួយភាគតូចបានចូលរួមវគ្គបណ្តុះបណ្តាលក៏ដោយ ក៏បទពិសោធន៏របស់ពួកគេជាទូទៅមានព្រំដែនកំណត់ទាក់ទងទៅនឹងប្រធានបទនេះ ។ តាមលទ្ធផលរបស់អ្នកត្រូវបានសម្ភាសន៏ជាច្រើននាក់ គឺមិនមានបទពិសោធន៏ក្នុងការធ្វើផែនការថវិកា ការគណនា និងចុះបញ្ជីក្រុមហ៊ុនទេ។ ភាគច្រើននៃពួកគាត់គឺយល់ពីទ្រឹស្តី ប៉ុន្តែបទពិសោធន៏មានព្រំដែនកំណត់។ ហេតុផលគឺពីព្រោះពួកគេបានប្រើតាមប្រភេទនៃការកត់ត្រាដែលជាទម្លាប់នៅក្នុងអាជីវកម្មរបស់ពួកគេ ។

**តារាង ៤: បទពិសោធន៏ និងចំណេះដឹងក្នុងគម្រោងថវិកា និងការតាមដាន និងការគណនានៃឱកាសថ្លៃដើម**

| **គំរោងថវិកា និងការតាមដាន និងការគណនានៃឱកាសថ្លៃដើម** | **គ្មានបទពិសោធន៏** | **មានបទពិសោធន៏ខ្លះៗ** | **មានបទពិសោធន៏ និងចំណេះដឹងច្រើន** |
|---|---:|---:|---:|
| ការគណនាចំណូលសំរាប់ថ្ងៃអនាគត | ៣៣ | ២៦ | ១ |
| តំលៃថេរ និងតំលៃប្រែប្រួល | ២៧ | ៣០ | ៣ |
| គណនាតំលៃផលិតផល | ២០ | ១៩ | ២១ |
| បង្កើនប្រាក់កម្ចីទៅតាមតំរូវការជំនួញ | ១៤ | ២៨ | ១៨ |
| ការគណនាទឹកប្រាក់សងប្រចាំឆ្នាំ ទៅលើបំណុល និងតំលៃការប្រាក់ | ២៨ | ១៧ | ១៥ |
| គណនាឱកាសថ្លៃដើម | ៩ | ៣៧ | ១៤ |
| បានទទួលពតិមានពីអ្នកចងការប្រាក់ និងថ្លៃការប្រាក់ | ៤ | ១១ | ៤៥ |

### 5.3.2 ការចុះបញ្ជីក្រុមហ៊ុន

មានតែអ្នកដែលធ្លាប់បានធ្វើការងារទាក់ទងនឹងកិច្ចការហិរញ្ញវត្ថុពីមុនទេ ទើបមានចំណេះដឹងខ្ពស់ពីប្រធានបទនេះ ជាពិសេសអ្នកដែលធ្វើការនៅក្រុមហ៊ុនពីមុនមក។ ជាក់ស្តែងស្ទើរគ្រប់អ្នកដែលធ្វើសម្ភាសន៍ គ្មានបទពិសោធន៍ទាក់ទងនឹងប្រធានបទនេះទេ ។

**តារាង ៥: បទពិសោធន៍ និងចំណេះដឹងក្នុងការចុះបញ្ជីក្រុមហ៊ុន**

| ការចុះបញ្ជីក្រុមហ៊ុន | គ្មានបទពិសោធន៍ | មានបទពិសោធន៍ខ្លះៗ | មានបទពិសោធន៍ និងចំណេះដឹងច្រើន |
|---|---|---|---|
| តើអ្នកមានបទពិសោធន៍ក្នុងការចុះបញ្ជី ជំនួញខ្នាត តូច រឺ មធ្យម ដែររឺទេ? | ៤១ | ១៦ | ៣ |
| តើអ្នកមានបទពិសោធន៍ក្នុងការចុះបញ្ជី ទ្វេភាគស្តីពីទុនចំណាយ និងទុនចំណូល (double entry) ដែររឺទេ? | ៥៦ | ៣ | ១ |
| តើអ្នកមានបទពិសោធន៍ក្នុងការរៀបចំបញ្ជី តុល្យភាពចំណូលចំណាយសំរាប់ក្រុមហ៊ុន (Balance sheet) ដែររឺទេ? | ៤៩ | ១០ | ១ |
| តើអ្នកមានបទពិសោធន៍ក្នុងការរៀបចំ របាយការណ៏ចំណូលចំណាយសំរាប់ ក្រុមហ៊ុនដែររឺទេ? | ៥០ | ៨ | ២ |




រូបភាពទី ១១: បទពិសោធន៍ក្នុងការចុះបញ្ជីក្រុមហ៊ុន

### 5.3.3 បច្ចេកទេសហិរញ្ញវត្ថុ

ជាងពាក់កណ្តាលនៃអ្នកត្រូវបានសម្ភាសន៏ បានផ្តល់ចំលើយវិជ្ជមានទាក់ទងទៅនឹងហិរញ្ញវត្ថុ។ ពួកគេទាំងអស់គ្នាគ្រប់គ្រងការងារទាំងអស់នេះតាមជំនួញសព្វថ្ងៃរបស់ពួកគេ ទោះជាពួកគេមិនបានយល់ច្បាស់ពីអត្ថន័យទាំងនេះក៏ដោយ។

**តារាង ៦: ការងារហិរញ្ញវត្ថុ**

| តើអ្នកយល់ពីអត្ថន័យទៅតាមអត្ថបទដូចខាងក្រោមនេះដែរឬទេ? | ចាំ | ទេ |
|---|---|---|
| ស្មើដើម | ៩៧ | ៣ |
| ដើមទុន | ៩៩ | ១ |
| តំលៃលក់ | ៤៧ | ១៣ |
| ការបញ្ចុះតំលៃកំរិតអប្បរមា | ៥៥ | ៥ |
| តំលៃថេរ | ៥៣ | ៧ |
| ទុនវិនិយោគ | ៥២ | ៨ |
| តំលៃបច្ចុប្បន្ន | ៤៨ | ១២ |
| ចំណូលពីការវិនិយោគ | ៣៨ | ២២ |
| ការប្រថុយប្រថាន | ៥៦ | ៤ |
| វិបត្តិហិរញ្ញវត្ថុ | ៥២ | ៨ |




**រូបភាពទី ១២: កំរិតយល់ដឹងនៃការងារហិរញ្ញវត្ថុ**

### 5.3.4 ការគ្រប់គ្រងក្រុមហ៊ុន

យើងអាចធ្វើការប្រមាណថា អ្នកត្រូវបានសម្ភាសន៏ ១៦.៦៦% មានបទពិសោធន៏នៅក្នុងការគ្រប់គ្រងគម្រោង ដូចជា ២០% មានបទពិសោធន៏ក្នុងផ្នែករដ្ឋបាលផ្ទាល់ខ្លួន ហើយប្រមាណជា ៣ ភាគ ៤ (៧០%) មានបទពិ-សោធន៏ ក្នុងការដឹកនាំមនុស្សក្នុងគម្រោង។

**តារាង ៧: ការគ្រប់គ្រងក្រុមហ៊ុន**

| ការគ្រប់គ្រងក្រុមហ៊ុន | គ្មានបទពិសោធន៏ | មានបទពិសោធន៏ខ្លះៗ | មានបទពិសោធន៏ និងចំណេះដឹងច្រើន |
|---|---|---|---|
| បទពិសោធន៏ក្នុងការគ្រប់គ្រងគម្រោង | ៣០ | ២០ | ១០ |
| បទពិសោធន៏ក្នុងការងាររដ្ឋបាល | ៣១ | ១៧ | ១២ |
| បទពិសោធន៏ក្នុងការដឹកនាំធនធានមនុស្សក្នុងគម្រោង | ៦ | ១២ | ៤២ |




**រូបភាពទី ១៣: ទំហំនៃការគ្រប់គ្រងគម្រោងដែលធ្លាប់មាន**

អ្នកត្រូវបានសម្ភាសន៏ទាំងអស់មានបទពិសោធន៏ក្នុងការគ្រប់គ្រងគម្រោង ឬរដ្ឋបាលផ្ទាល់ខ្លួន ភាគច្រើនពួកគាត់គ្រប់គ្រង ឬក្រុមការងារ ជាមួយសមាជិកមិនតិចជាង ១០ នាក់។ ជាមធ្យមដឹកនាំមនុស្សក្នុងគម្រោង ៤ នាក់។

# 6 សេចក្ដីសន្និដ្ឋានរួម

មនុស្សនៅតាមក្រុមគោលដៅទាំងអស់សុទ្ធតែទទួលចំណេះដឹងពីសាលា។ ភាគច្រើនឈប់រៀនបន្ទាប់ពីចប់បឋមសិក្សា, វិទ្យាល័យ ឬក៏រិតបាក់ឌុប។ មានតែអ្នកត្រូវបានសម្ភាសន៍មួយចំនួនតូចប៉ុណ្ណោះ ដែលទទួលបានការអប់រំខ្ពស់ដូចជា បរិញ្ញាបត្រ ឬអនុបណ្ឌិត។

សិប្បកម្មមានបទពិសោធន៍ក្នុងការងាររបស់ពួកគេបច្ចុប្បន្ន ៩ ឆ្នាំ ជាមធ្យម និង ១០ ឆ្នាំ ក្នុងការងាររបស់គេពីមុន។ ជាងពាក់កណ្ដាលនៃពួកគេគឺរៀនដោយខ្លួនឯង លើការងារគណនេយ្យផ្ទាល់ខ្លួន វគ្គបណ្ដុះបណ្ដាលពិសេសដូចជា ហិរញ្ញវត្ថុ ការគ្រប់គ្រង និងគណនេយ្យ។ អ្នកដែលបានចូលរួមវគ្គបណ្ដុះបណ្ដាល ទំនងជាមានបទពិសោធន៍នៅក្នុងផ្នែកទាំងអស់នោះ។ ទោះបីជាពួកគេមិនប្រើនូវចំណេះដឹងដែលមានក្នុងការងារជាប្រចាំ ក៏ពួកគេដឹងអំពីការងារទាក់ទងជំនួញ និងហិរញ្ញវត្ថុដែរ ដូចមានបង្ហាញតាមរូបភាពទី ១១។

ថ្វីបើភាគច្រើនមានចំណេះដឹងខ្លះៗអំពីអត្ថន័យនៃការងារហិរញ្ញវត្ថុក៏ដោយ ក៏ពួកគេបានទទួលពត៌មានយ៉ាងទូលំ-ទូលាយ អំពីការចុះបញ្ជីក្រុមហ៊ុន និងគម្រោងថវិកាផងដែរ។ ជាពិសេសអ្វីដែលទាក់ទងទៅនឹងការចុះបញ្ជី គឺពួកគេមិនមានបទពិសោធន៍។ ហេតុផលដោយសារជំនួញរបស់ពួកគេមានលក្ខណៈប្រព័ន្ធទ្រង់ទ្រាយតូច។ មានតែអ្នកធ្វើការនៅក្នុងក្រុមហ៊ុនដែលអាចឆ្លើយតបទៅនឹប្រធានបទនេះបាន ដោយសារមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់។

បទពិសោធន៍ក្នុងការគ្រប់គ្រងក្រុមហ៊ុនមិនមានលក្ខណៈតាមស្តង់ដា។ ជាងពាក់កណ្ដាលនៃអ្នកត្រូវបានសម្ភាសន៍មិនមានបទពិសោធន៍ក្នុងការគ្រប់គ្រងគម្រោងទេ ទោះជាមាន ៧0% គ្រប់គ្រងគម្រោងផ្ទាល់ខ្លួនក៏ដោយ ។

អ្នកចូលរួមភាគច្រើននៅក្នុងក្រុមគោលដៅធ្វើការ និងដឹកនាំជំនួញធុនតូច។ គម្រោងដែលមានទំហំធំជាងគេ តែងតែគ្រប់គ្រងថវិកាតិចជាង ៥000 ដុល្លាសហរដ្ឋអាមេរិក។

បញ្ជីសំនួរបង្ហាញថា មានមនុស្សដែលទទួលបទពិសោធន៍ទូលំទូលាយនៅក្នុងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនឹងមិនបានទទួលចំណេះដឹងច្បាស់លាស់ណាមួយទេ។ តាំងពីប្រធានបទជាច្រើនពុំមានការទាក់ទងដល់ការងាររាល់ថ្ងៃ បទពិ-សោធន៍របស់ពួកគេ និងចំណេះដឹងនូវមានកំរិតទាប។ តាមលទ្ធផលនៃបញ្ជីសំនួរបង្ហាញពី សារៈសំខាន់នៃការបង្កើនចំណេះដឹងផ្នែកហិរពាវត្ថុ និងការងារសេដ្ឋកិច្ច។ រួមជាមួយបទពិសោធន៍ទៅតាមប្រធានបទទាំងនេះអ្នកត្រូវបានសម្ភាសន៍អាចពង្រីកជំនួញផ្ទាល់ខ្លួន និងដោះស្រាយបញ្ហាជាមួយក្រុមហ៊ុនធំៗជាមួយការខាតបង់នៃកំហុសបន្តិចបន្តួច ដោយសារការខ្វះខាតចំណេះដឹង។

# 7 សេចក្តីបន្ថែម

## 7.1 សេចក្តីបន្ថែម 1: Questionnaire

# បញ្ជីសំណួរ

# លើចំណេះដឹងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

កាលបរិច្ឆេទនៃបញ្ជីសំណួរ:..............................................

**1-** ពត៌មានផ្ទាល់ខ្លួនទូទៅ

1. ភេទ:......................................
2. អាយុ:.....................................
3. មុខរបរបុច្ចប្បន្ន:.........................
4. តួនាទីសព្វថ្ងៃ:.........................................
5. រយ:ពេលបទពិសោធន៏ការងារបច្ចុប្បន្ន:.................ឆ្នាំ
6. មុខរបរពីមុន:......................................................
7. បទពិ-សាធន៏ក្នុងមុខរបរពីមុន:................................

**2-** ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីកំរិតនៃការសិក្សា (អាចគូសបានច្រើនជាងមួយ)

1. ☐ សាលាបឋម (ថ្នាក់ ១-៦)
2. ☐ អនុវិទ្យាល័យ (ថ្នាក់ ៧-៩)
3. ☐ វិទ្យាល័យ (ថ្នាក់ ១០-១២)
4. ☐ បានរៀនវិជ្ជាជីវ:
5. បានរៀនមហាវិទ្យាល័យ ក្នុងកំរិតណា
   ☐ បរិញ្ញាបត្រ, ☐ អនុបណ្ឌិត, ☐ បណ្ឌិត
6. ផ្សេងៗ............................

**3-** ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីមុខវិជ្ជាដែលបានសិក្សា

1. ☐ វិស្វករ/អ្នកបច្ចេកទេស
2. ☐ អ្នកសេដ្ឋកិច្ច
5. ☐ វិទ្យាសាស្ត្រធម្មជាតិ
6. ☐ វិទ្យាសាស្ត្រសង្គម

3. ☐ អ្នកជំនួញ/អ្នកគ្រប់គ្រង 7. ☐ ផ្សេងៗ.............................................................

4. ☐ មនុស្សធម៌

បើសិនអ្នកធ្លាប់រៀនលើជំនាញដែលមានរយៈពេលខ្លីសូមធ្វើការបញ្ជាក់នៅខាងក្រោម :

1. មុខវិជ្ជាអ្វី.........................................................................................................................

2. ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីរយៈពេលនៃការសិក្សា

☐ មួយថ្ងៃ ☐ មួយសប្តាហ៍ ☐ មួយខែ ច្រើនជាងមួយខែ.................................

**4-** កំរិតនៃការយល់ដឹង បទពិសោធន៍ និងលទ្ធភាពហិរញ្ញវត្ថុ

បទពិសោធន៍ធ្វើផែនការ និងការវាយតំលៃចំណូលចំណាយ និងចំណេះដឹងទៅលើការទាញយកប្រយោជន៍ពីថវិកាដែលមាន ( ឱកាសតំលៃ )

3 = មានបទពិសោធន៍ច្បាស់, 2 = មានបទពិសោធន៍ខ្លះ, 1 = មិនមានបទពិសោធន៍

– តើអ្នកមានបទពិសោធន៍ក្នុងការគណនាតំលៃជាក់ស្តែងបច្ចុប្បន្ន ដើម្បីរៀបចំផែនការចំណូលសំរាប់ថ្ងៃអនាគតដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

☐ 3 ☐ 2 ☐ 1

– តើអ្នកមានតំលៃថេរ (Fixed cost) និងតំលៃប្រែប្រួល (Variable cost) ដែរឬទេ?

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

☐ 3 ☐ 2 ☐ 1

– តើអ្នកមានពិសោធន៍ក្នុងការគណនាតំលៃផលិតផលដែររឺទេ? ( ឧទា, តំលៃភ្លើង)

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

□ 3 □ 2 □ 1

- តើអ្នកមានបទពិសោធន៍ក្នុងការបង្កើនប្រាក់កំចីទៅតាមតំរូវការជំនួញរបស់អ្នកដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ □ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

□ 3 □ 2 □ 1

- តើអ្នកមានបទពិសោធន៍ក្នុងការគណនា ទឹកប្រាក់សងប្រចាំឆ្នាំទៅលើបំណុល និងតំលៃការប្រាក់ដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ □ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

□ 3 □ 2 □ 1

- តើអ្នកមានបទពិសោធន៍ក្នុងការប្រើប្រាស់ឱកាសតំលៃដើម្បីស្វែងរកប្រាក់ចំណេញតាមទិសដៅថវិកាដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ □ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

□ 3 □ 2 □ 1

- តើអ្នកធ្លាប់បានទទួលពតិមានពីអ្នកចងការប្រាក់ និងថ្លៃការប្រាក់របស់ពួកគេដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ □ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

□ 3 □ 2 □ 1

**5-** ការចុះបញ្ជីក្រុមហ៊ុន

3 = មានបទពិសោធន៍ច្បាស់, 2 = មានបទពិសោធន៍ខ្លះ, 1 = មិនមានបទពិសោធន៍

- តើអ្នកមានបទពិសោធន៍ក្នុងការចុះបញ្ជីជំនួញខ្នាត តូច រឺ មធ្យម ដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ □ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

☐ 3 ☐ 2 ☐ 1

- តើអ្នកមានបទពិសោធន៏ក្នុងការចុះបញ្ជីទ្វេភាគស្តីពីទុនចំណាយនិងទុនចំណូល (double entry) ដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីបទពិសោធន៏របស់អ្នក

☐ 3 ☐ 2 ☐ 1

- តើអ្នកមានបទពិសោធន៏ក្នុងការរៀបចំបញ្ជីតុល្យភាពចំណូលចំណាយសំរាប់ក្រុមហ៊ុន (Balance sheet) ដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីបទពិសោធន៏របស់អ្នក

☐ 3 ☐ 2 ☐ 1

- តើអ្នកមានបទពិសោធន៏ក្នុងការរៀបចំរបាយការណ៏ចំណូលចំណាយ សំរាប់ក្រុមហ៊ុនដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីបទពិសោធន៏របស់អ្នក

☐ 3 ☐ 2 ☐ 1

**6. តើអ្នកយល់អត្ថន័យទៅតាមអត្ថបទដូចខាងក្រោមនេះដែររឺទេ?**

Breakeven point (ស្មើដើម)

មានន័យថាចំណូលសាច់ប្រាក់ដែលបានពីការលក់ មានតំលៃស្មេទៅនឹងតំលៃទិញចូល។ ជាញឹកញាប់គេតែងតែនិយាយថាគេលក់របស់ត្រឹមថ្លៃ។ ការលក់លើតំលៃស្មើដើមមានន័យថា យើងមិនបានចំណេញតែបើលក់ក្រោមតំលៃដើមមានន័យថាយើងខាត។

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

☐ យល់ ☐ មិនយល់

Capital ដើមទុន

គឺសាច់ប្រាក់ដែលមានដំបូងសំរាប់វិនិយោគទុនលើជំនួញណាមួយ។ នៅផ្នែកខាងក្រោម រឺខាងស្តាំនៃតារាង-តុល្យាភាព ចំណាយចំណូលមានបញ្ចូលខ្ទង់ដើមទុនផងដែរសំរាប់ការចំណាយទៅលើ អាគារ ម៉ាស៊ីន និងគ្រឿ-ងប្រើ ប្រាស់ផ្សេងៗទៀត។

ការបោះដើមទុន មានន័យថាគឺជាការធ្វើវិនិយោគទុនលើគ្រឿងបរិក្ខាដែលប្រើប្រាស់ក្នុងរយៈពេលយូរ។

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីកំរិតយល់ដឹងរបស់អ្នក

☐ យល់ ☐ មិនយល់

Cost of sales, cost of good sold (**តំលៃលក់**)

| |
|---|
| **តំលៃលក់** = តំលៃនៅក្នុងស្តុកដំបូង + ប្រាក់ចំណាយទិញទំនិញចូលបច្ចុប្បន្ន-តំលៃសំណល់ក្នុងស្តុកចុងក្រោយ |

- **តំលៃក្នុងស្តុកដំបូង:** ជាតំលៃសរុបទៅលើតវ៉ាន់ទាំងអស់មាននៅក្នុងស្តុកដំបូង ។
- **ប្រាក់ចំណាយទិញទំនិញចូលបន្ថែម:** ជាតំលៃដែលចាយទៅលើការទិញតវ៉ាន់បន្ថែម នៅអំឡុងដំណើរការលក់ដូរទំនិញ ។

- **តំលៃសំណល់ក្នុងស្តុកចុងក្រោយ:** ជាតំលៃដែលមាននៅក្នុងឥវ៉ាន់ក្នុងស្តុកចុក្រោយ ពេលយើងបិទបញ្ជីចំណូល ។

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីកំរិតយល់ដឹងរបស់អ្នក

☐ យល់ ☐ មិនយល់

Discounted cash flow (ការបញ្ចុះតំលៃកំរិតអប្បបរមា)

ប្រព័ន្ធនេះគេប្រើសំរាប់ ឱកាសវិនិយោគ ដោយបញ្ចុះតំលៃទំនិញកំរិតអប្បបរមា ។

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីកំរិតយល់ដឹងរបស់អ្នក

☐ យល់ ☐ មិនយល់

Fixed cost (តំលៃថេរ)

ជាតំលៃដែលមិនមានការផ្លាស់ប្តូរតាមកំរិតនៃការលក់ (ក្នុងរយៈពេលខ្លី) ។ ជាធម្មតាតំលៃថេរ មានរួមបញ្ចូលថ្លៃជួលផ្ទះ ថ្លៃលក់ចេញ ការប្រាក់ និង ប្រាក់ខែ ។

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីកំរិតយល់ដឹងរបស់អ្នក

☐ យល់ ☐ មិនយល់

Invested Capital (ទុនវិនិយោគ)

គឺជាសាច់ប្រាក់សរុបទាំងអស់របស់ក្រុមហ៊ុនរួមទាំងបំណុល និងអចលនទ្រព្យ ។

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីកំរិតយល់ដឹងរបស់អ្នក

☐ យល់ ☐ មិនយល់

## Present Value (តំលៃបច្ចុប្បន្ន)

គឺជាទំរង់នៃការប្រៀបធៀបទឹកប្រាក់ដែលមានក្នុងដៃទៅនឹងសាច់ប្រាក់ក្នុងថ្ងៃអនាគត។ ឧទា. $78.35 បានត្រូវដាក់វិនិយោគថ្ងៃនេះទៅក្នុង 5% នៃគណនីសន្សំដែលនឹងកើនឡើង $100 ក្នុងរយៈពេលប្រាំឆ្នាំក្រោយ។ ដូចនេះ តំលៃបច្ចុប្បន្ននៃ $100 គឺទទួលពីកំណើនការប្រាក់ក្នុងរយៈពេលប្រាំឆ្នាំពីសាច់ប្រាក់ $78.35។ ទំរង់នៃតំលៃបច្ចុប្បន្ន គឺជាការវិភាគនូវឱកាសវិនិយោគដែលទទួលបាននៅពេលអនាគត។

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីកំរិតយល់ដឹងរបស់អ្នក

☐ យល់ ☐ មិនយល់

## Return on investment (ROI) (ចំណូលពីការវិនិយោគ)

គឺជាការវាស់វែងដែលមានប្រសិទ្ធភាព និងបានផលចំណេញទៅតាមអ្នកគ្រប់គ្រងដែលប្រើប្រាស់ធនធានដែលមានស្រាប់សំរាប់ពួកគាត់ដោយគិតជាភាគរយ។

ចំណូលពីអចលនទ្រព្យគេគិតបាន នៅពេលដែលគេដកការចំណាយទៅលើ ការបង់ពន្ធ និងការប្រាក់ចេញ។

ចំណូលពីការដាក់ទុនវិនិយោគគឺ ជាធម្មតាទទួលប្រាក់ចំណេញបន្ទាប់ពីបានបង់ពន្ធ និងការប្រាក់ដែលជាបំណុលរយៈពេលយូររួមជាមួយបំណុលអចលនទ្រព្យរយៈពេលយូរ។

ចំណូលពីចលនទ្រពជាប្រាក់ចំណេញពេលដែលបានបែងចែកការប្រើប្រាស់ ចលនទ្រព្យទៅតាមការផលិតដើម្បីរកចំណេញ។

ចំណូលពីការវិនិយោគ មានប្រយោជន៍សំរាប់ធ្វើការប្រៀបធៀបតាមក្រុមហ៊ុនស្រដៀងគ្នា រឺក្រុមហ៊ុនដូចគ្នាឧស្សាហកម្មតែមួយ នៅក្នុងកំឡុងពេលដូចគ្នា។

ចូរគូស √ នៅក្នុងប្រអប់ ☐ បញ្ជាក់ពីកំរិតយល់ដឹងរបស់អ្នក

☐ យល់ ☐ មិនយល

## Risk (ការប្រថុយប្រថាន)

គឺជាដំណើរមួយដែលមានការបាត់បង់ នៅក្នុងរាល់សកម្មភាពជំនួញ។ ការប្រថុយប្រថានកាន់តែខ្ពស់គឺកំរិតខាតបង់ការ កាន់តែធំ។ រាល់ជំនួញទាំងអស់ធ្វើការសំរេចចិត្តផ្អែកលើបរិមាណនៃការប្រថុយ ប្រថាន។

ចូរគូស √ នៅក្នុងប្រអប់ □ បញ្ជាក់ពីការិតយល់ដឹងរបស់អ្នក

□ យល់ □ មិនយល

Sunk Costs (វិបត្រហិរញ្ញវត្ថុ)

នៅពេលដែលសាច់ប្រាក់ត្រូវបានចំណាយ មិនអាចរ៉ាប់រងបានទៅលើរាល់សកម្មភាព ពេលនោះការធ្វើសេចក្តីសំរេចចិត្ត ដែលមិនមានភាពប្រកតីមួយនឹងកើតមានឡើងនៅសំរាប់ដោះស្រាយវិបត្រនេះ ។

ចូរគូស √ នៅក្នុងប្រអប់ □ បញ្ជាក់ពីការិតយល់ដឹងរបស់អ្នក

□ យល់ □ មិនយល

**៧. ការគប់គ្រងក្រុមហ៊ុន**

3 = មានបទពិសោធន៍ច្បាស់, 2 = មានបទពិសោធន៍ខ្លះ, 1 = មិនមានបទពិសោធន៍

- តើអ្នកមានបទពិសោធន៍ក្នុងការគ្រប់គ្រងគំរោងដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ □ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

□ 3 □ 2 □ 1

- តើអ្នកមានបទពិសោធន៍ផ្នែករដ្ឋបាលដែររឺទេ?

ចូរគូស √ នៅក្នុងប្រអប់ □ បញ្ជាក់ពីបទពិសោធន៍របស់អ្នក

□ 3 □ 2 □ 1

- ទំហំនៃគំរោងដ៏ធំដែលមានសាច់ប្រាក់ប្រមាណជាដុល្លាសហរដ្ឋអាមេរិក:...........................

- ចំនួនមនុស្សដែលដឹកនាំនៅក្នុងគំរោងនោះ:

□ 1-3, □ 3-5, □ 6-10

លើសពីនេះ: ..........................................................................................................

## 7.2 សេចក្តីបន្ថែម 2: Excel files with the single results without graphs

C:\Documents and Settings\USER\My Documents\Admin\Project of REEPRO\2_Education scan\Completed Task

# 8 ឯកសារយោង

Survey of questionnaires through 60 households

**Websites**

http://www.adb.org/Documents/CSPs/CAM/2006/COBP-CAM-2006.pdf

www.wikipedia.org

http://www.moeys.gov.kh/profile/edu_in_cambodia/quality_efficiency.htm

http://www.moeys.gov.kh/en/education/espr05/2-1education.htm#1.6